# សង្ខេបរបាយការណ៍
# សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ
# មនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧
# និងទិសដៅ ឆ្នាំ២០១៨

(គិតចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧)

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨

# មាតិកា

I. ស្ថានភាពទូទៅ
II. យុទ្ធសាស្ត្រ ប្រឆាំងអំពើជួញដូរមនុស្ស
ក. ការងារច្បាប់គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ
ខ. ការងារបង្ការទប់ស្កាត់
គ. ការងារអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌
ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ
IV. . ការលើកកម្ពស់សមត្ថភាព
V. ការសន្និដ្ឋាន វាយតម្លៃ
VI. ទិសដៅ ឆ្នាំ២០១៨

# I. ស្ថានភាពទូទៅ

- **សន្តិភាព** និង ស្ថេរភាពនយោបាយ គឺជាកត្តាគន្លឹះ និងជាមូលដ្ឋានគ្រឹះដែលនាំឲ្យព្រះរាជាណាចក្រកម្ពុជាមានឱកាសនៅក្នុងការជម្រុញការរីកចម្រើនលើគ្រប់វិស័យ ។
- ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** តែងតែយកចិត្តទុកដាក់ជាសំខាន់ លើការគោរពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យដែលជាមូលដ្ឋានគ្រឹះនៃសន្តិភាព និងការអភិវឌ្ឍ ។
- ក្នុងនោះ រាជរដ្ឋាភិបាលបានខិតខំជម្រុញការធ្វើកំណែទម្រង់សំខាន់ៗ និងពង្រឹងកិច្ចការពារបូរណភាពទឹកដី និងសន្តិសុខជូនប្រជាពលរដ្ឋ ព្រមទាំងលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្របានដោយជោគជ័យ តាមរយៈការស្វែងរកឱកាសការងារ ឬមុខរបរ ខ្នាតតូច មធ្យម ឬធំ សម្រាប់ប្រជាពលរដ្ឋ ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។
- ទន្ទឹមនឹងនោះ ប្រជាពលរដ្ឋកម្ពុជាជាងមួយលាននាក់ បាន និងកំពុងអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងការធ្វើចំណាកស្រុក ស្វែងរកការងារធ្វើនៅក្រៅប្រទេស ដែលប្រមាណ ៧០% មិនបានទៅតាមប្រព័ន្ធច្បាប់ និងត្រូវប្រឈមនឹងការរំលោភបំពានផ្នែកច្បាប់ និងអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ច ជាច្រើនរូបភាព ។
- រាជរដ្ឋាភិបាល បានខិតខំដោះស្រាយបញ្ហា និងភាពប្រឈមទាំងឡាយ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ រាប់ទាំង ការកសាងច្បាប់ គោលនយោបាយ លិខិតបទដ្ឋាន យន្តការ និងសេវាចាំបាច់ផ្សេងៗ ក្នុងនោះ មានទាំងការចុះកិច្ចព្រមព្រៀងជាមួយប្រទេសគោលដៅ ការផ្តល់ភាពស្របច្បាប់ជូនពលករ ដែលបាន និងកំពុងស្នាក់នៅធ្វើការខុសច្បាប់ ក្នុងប្រទេសថៃ និងការបើកកន្លែងផ្តល់លិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតការងារ នៅទីតាំងសំខាន់ៗមួយចំនួន ក៏ជាដំណោះស្រាយមួយ ដើម្បីការការពារពលករពីការរំលោភបំពាន និងកេងប្រវ័ញ្ច ក្នុងរូបភាពជាពលករខុសច្បាប់ ។
- ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាច្រើនទៀត ដើម្បីការពារឧត្តមប្រយោជន៍របស់ពលករកម្ពុជានៅក្នុង និងក្រៅប្រទេស។
- ដោយឡែក គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បាន និងកំពុងតែអនុវត្តយុទ្ធសាស្ត្រ និងផែនការរបស់ខ្លួនតាមរយៈយន្តការ ដែលបានរៀបចំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

# II. ការអនុវត្តយុទ្ធសាស្ត្រ ប្រឆាំងអំពើជួញដូរមនុស្ស

# ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

កិច្ចការនេះ ត្រូវបានយកចិត្តទុកដាក់តាំងពីថ្នាក់កំពូលដល់មូលដ្ឋាន

**កិច្ចការអន្តរជាតិ៖**

- **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** បានចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងបានចុះហត្ថលេខាលើអនុសញ្ញាអាស៊ាន ប្រឆាំងការជួញដូរមនុស្ស និងផែនការសកម្មភាពអាស៊ាន ។
- **ក្រុមការងារខមមីត** បានបន្តសហការជាមួយប្រទេសពាក់ព័ន្ធដើម្បីបន្តអនុវត្តផែនការ SPA 4 ។
- **គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលចិន ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានប្រជុំប្រចាំឆ្នាំលើកទី១ នៅខេត្តអានហ្វួយ ប្រទេសចិន និងចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយរដ្ឋាភិបាលឥណ្ឌា ស្តីពីកិច្ចសហការបង្ការទប់ស្កាត់ និងប្រឆាំងអំពើជួញដូរមនុស្ស។
- **ក្រសួងការងារបណ្តុះ បណ្តាលវិជ្ជាជីវៈ** ៖ បានចុះអនុស្សរណៈចំនួនពីរ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ ជាមួយសមាគមន៍ធនធានមនុស្ស នៅតំបន់រដ្ឋបាលហុងកុង និងជាមួយក្រសួងការងារជនពិការ និងសង្គមកិច្ច នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- **ក្រសួងយុត្តិធម៌៖**
  - បានចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពី“**បត្យាប័ន**” ចំនួន០២ ជាមួយ ប្រទេសរុស្ស៊ី និងប្រទេសបារាំង
  - ចុះសន្ធិសញ្ញា ស្តីពី “**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**” ចំនួន ០២ សន្ធិសញ្ញាស្តីពី“ការផ្ទេរទណ្ឌិត”ចំនួន ០២ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសវៀតណាម និងប្រទេសរុស្ស៊ី។
  - ចុះកិច្ចព្រមព្រៀងពីរទៀត ជាមួយក្រសួងយុត្តិធម៌វៀតណាម និងចុះអនុស្សរណៈរវាងរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការកម្ពុជា និងបណ្ឌិត្យសភាតុលាការវៀតណាម ។

# ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ (ត)

## កិច្ចការថ្នាក់ជាតិ ៖

- **រាជរដ្ឋាភិបាល**បានដាក់ចេញអនុក្រឹត្យចំនួនពីរ ស្ដីពី «ប័ណ្ណព្រំដែន កម្ពុជា-ឡាវ» និងស្ដីពី «ការលុបចោល និងដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី»
- **ក្រសួងមហាផ្ទៃ និងក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ** បានចេញ**ប្រកាសអន្តរក្រសួង** ស្ដីពីនីតិវិធី និងបែបបទ នៃការចេញ ការដកហូត ការបដិសេធ លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ។ ក្រសួងមហាផ្ទៃ បានចេញសេចក្តីជូនដំណឹង ដល់អាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីដោះស្រាយ ករណីពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជា ជាដើម ។
- នៅមានលិខិតបទដ្ឋានមួយចំនួនទៀត តាមបណ្តាក្រសួង និងរដ្ឋបាលរាជធានីខេត្ត បានដាក់ចេញ ដើម្បីសម្រួល និងពង្រឹងកិច្ចប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

# ខ. ការទារបង្ការទប់ស្កាត់

ត្រូវបានធ្វើឡើងតាមវិធីជាច្រើនៈ

១. ការចុះត្រួតពិនិត្យតាមបណ្តាច្រកព្រំដែន ដើម្បីប៉ាន់ប្រមាណពីលំហូរចេញ ចូលរបស់ពលករ ទាំងតាមច្រកផ្លូវការ និងមិនផ្លូវការ នៅតាមខ្សែបណ្តាយព្រំដែនកម្ពុជា-ថៃ

២. ការទប់ស្កាត់លំហូរពលករទៅក្រៅប្រទេស តាមរយៈដាក់ចេញនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករនៅតាមបណ្តារោងចក្រ សហគ្រាស និងលើកកម្ពស់លក្ខ័ណ្ឌការងារ ការអនុវត្តរបបសន្តិសុខសង្គម និងរបបសោធននិវត្តន៍។

៣. ការជម្រុញកំណើនសេដ្ឋកិច្ចជនបទឲ្យបានប្រហាក់ប្រហែលទីប្រជុំជន  របស់ក្រសួងអភិវឌ្ឍន៍ជនបទ

៤..ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករឯកជន ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលើទីភ្នាក់ងារឯកជន ចំនួន ៨៥ ដែលបានបញ្ជូនពលករទៅក្រៅប្រទេស។

ទីភ្នាក់ងារឯកជន និង ប្រព័ន្ធអនុគ្រោះមុខរបរ របស់រដ្ឋាភិបាល បានបញ្ជូនពលករ ចំនួន ៤៥ ៧៩៧នាក់ ស្រី ១៨ ២៨០នាក់ ទៅប្រទេសចំនួន ៧។

៥. កាត់បន្ថយភាពរងគ្រោះដល់មុខសញ្ញាងាយរងគ្រោះជាពិសេសស្ត្រី និងកុមារ ដោយប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ស្នងការដ្ឋាននគរបាល ខេត្ត មន្ទីរសង្គមកិច្ច អធិការដ្ឋាននគរបាលស្រុក និងតាមបណ្តាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់។

# ខ. ការទារបង្ការទប់ស្កាត់ (ត)

**៦. ការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ** គឺត្រូវបានធ្វើឡើង ជាច្រើនរូបភាព ក្នុងនោះមាន

- កម្មវិធីសូត្រធម៌ អធិដ្ឋាន បញ្ជូនសារតាមបែបអន្តរសាសនា ដើម្បីប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដែលមានអ្នកដឹកនាំ និងសាសនិកសាសនា ចម្រុះ ចូលរួមប្រមាណ ១២០០ អង្គ នាក់ ។
- យុទ្ធនាការក្នុងទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តដោយមានការចូលរួម យ៉ាងផុលផុសពីគ្រប់សមាសភាព ក្នុងអង្គការនីតិបញ្ញត្ត នីតិប្រតិបត្តិ តុលាការ កងកម្លាំងប្រដាប់អាវុធ គ្រប់ផ្នែក វិស័យឯកជន សង្គមស៊ីវិល សាលារៀន សាកលវិទ្យាល័យ និងប្រជាពលរដ្ឋ សរុបប្រមាណ ជិត ៦សែននាក់ ។
- ការដាក់បញ្ចូលខ្លឹមសារអប់រំអំពីអំពើជួញដូរមនុស្ស គ្រោះថ្នាក់នៃភាពប្រថុយប្រថានឆ្លងដែនខុសច្បាប់ ផលប៉ះពាល់នៃទេសន្តរប្រវេសន៍ និងចំណាកស្រុកដោយសុវត្ថិភាព ទៅក្នុងវេទិកាសាធារណៈ តាមបណ្តាភូមិឃុំ ក្នុងការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ត្រូវបានធ្វើឡើងចំនួន៥២.៨៧៩លើក មានអ្នកចូលរួមសរុបចំនួន៤.៩៥៩.៩៣៨នាក់ កើនលើសឆ្នាំ ២០១៦ ប្រមាណ ៣២,៦១% ។
- ក្រសួងអប់រំយុវជន និងកីឡា ចុះផ្សព្វផ្សាយការយល់ដឹងដោយ ដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត តាមសាលវិទ្យាល័យ សិស្សតាមសាលារៀន និងដាក់បញ្ចូលបញ្ចូលខ្លឹមសារអប់រំអំពីការបង្ការទប់ស្កាត់ និងផលប៉ះពាល់នៃអំពើជួញដូមនុស្ស និងអំពើកេងប្រវ័ញ្ចផ្លូវភេទ ក្នុងកម្មវិធីសិក្សាតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន បានចំនួន**១.០៣៧**គ្រឹះស្ថានសិក្សា និងសកលវិទ្យាល័យចំនួន **១២** នៅទូទាំងប្រទេស ។
- ក្រសួងធម្មការ និងសាសនា បានបញ្ជ្រាបការយល់ដឹង សុជីវធម៌ គុណធម៌ សីលធម៌ តាមរយៈព្រះសង្ឃជាធម្មកថិកាចារ្យល្បីៗ ដែលមានទេពកោសល្យខ្ពស់ក្នុងការសំដែងធម្មទេសនាដោយផ្សារភ្ជាប់ព្រះពុទ្ធសាសនាទៅក្នុងសង្គម ដើម្បីលើកកម្ពស់ការយល់ដឹង និងពាក់ព័ន្ធ ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន៨៣អង្គ និងមានការចូលរួមស្តាប់មកពីគ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំរដ្ឋ ឯកជន មហាជនជាពុទ្ធបរិស័ទចំនួន៤.៤៨៣នាក់ និងព្រះសង្ឃចំនួន៥៣៤អង្គ នៅតាមបណ្តា រាជធានី-ខេត្ត។

# ខ. ការទារបង្ការទប់ស្កាត់ (ត)

## ៧. ការផ្សព្វផ្សាយ តាមប្រព័ន្ធព័ត៌មាន និងសម្ភារៈផ្សព្វផ្សាយអប់រំ

- ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសង្គមគ្រប់រូបភាព តាមរយៈការផលិតបទយកការណ៍ រឿងអប់រំខ្លី ខ្សែភាពយន្ត វីដេអូ ស្ប៉ត់ ចាក់ផ្សាយតាមវិទ្យុ និងទូរទស្សន៍ ការចូលរួមកិច្ចសន្ទនា បកស្រាយតាមកម្មវិធីវិទ្យុ និងទូរទស្សន៍នានា
- អង្គការ Cambodia Acts បានផលិត DVD CD ស្តីពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស និងសហការជាមួយក្រសួងកិច្ចការនារី ចូលរួមជាវាគ្មិន ក្នុងកម្មវិធីទូរទស្សន៍ជាតិកម្ពុជាចំនួន០១លើក ស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបន្ទាល់ទី ។
- ក្រសួងធម្មការ និងសាសនា បានផលិត DVCamsចំនួន១.០១២ដុំ និងCD សម្លេងចំនួន៧៧០បន្ទះ ស្តីពីផលប៉ះពាល់នៃការជួញដូរមនុស្ស ហើយចាក់ផ្សាយតាមវិទ្យុ ចំនួន២៣ស្ថានីយ៍ និងតាមទូរទស្សន៍ ចំនួន២៣ស្ថានីយ៍។
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយផលិតកម្មភាពយន្ត បានដាក់បញ្ចូលសារអប់រំស្តីពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចពលកម្មកុមារ ការជួញដូរភេទក្នុងផលិតផលខ្សែភាពយន្ត វីដេអូចម្រៀងកាយវិការ និងខារ៉ាអូខេ ព្រមទាំងផលិតទស្សនីយភាព ល្ខោននិយាយ សម្តែងជាច្រើនរឿង ដើម្បីសម្តែង ក្នុងកម្មវិធី និងពិធីបុណ្យជាតិផ្សេងៗ ។
- អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ បានសហការជាមួយទូរទស្សន៍ PNN និងទូរទស្សន៍បាយ័ន ផលិត បទយកការណ៍ ដើម្បីចាក់ផ្សាយ ក្នុងកម្មវិធីយុទ្ធនាការទិវាជាតិ ១២ធ្នូ ២០១៧ ។ បានបញ្ជូនមន្ត្រីជំនាញពី អគ្គលេខាធិការដ្ឋាន ចូលរួមជាវាគ្មិន ក្នុងកិច្ចសន្ទនាតាមកម្មវិធីនានា របស់ទូរទស្សន៍ជាតិ ទូទស្សន៍ បាយ័ន BTV, PNN, Nice, CTN វិទ្យុសារិកា វិទ្យុវាយោ ជាដើម ។

# ខ. ការទារបង្ការទប់ស្កាត់ (ត)

- ការផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ ធ្វើឡើងដោយមន្ទីរ ស្ថាប័ន អង្គភាពពាក់ព័ន្ធ មាន៖
- **លេខាធិការដ្ឋានគ.ខ.ប.ជ** បានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន**២២៦**លើក មានខេត្តកោះកុង**១៥៨**លើក, សៀមរាប**២៨**លើក, កំពង់ចាម**០៣**លើក បាត់ដំបង**២៦**លើក ក្រចេះ**០២**លើក និងកំពត**០៩**លើក។
- **ខេត្តប៉ៃលិន** បានបិទផ្សព្វផ្សាយខ្លឹមសារច្បាប់ និងសេចក្តីណែនាំលេខ០៤៥ ស.ណ.ន ទាក់ទងនឹងអំពើជួញដូរមនុស្ស តាមគោលដៅចំនួន**៨៩**កន្លែង។
- **ខេត្តកំពត** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានចែកឌីស និងបញ្ចាំងវីដេអូអប់រំ ផ្សព្វផ្សាយផលប៉ះពាល់នៃការធ្វើចំណាកស្រុក ស្តីពី“ដើងមេឃនៅឯណា” បានចំនួន**៤០០**ឌីសតាមបណ្តាស្រុកទូទាំងខេត្ត សរុបបានចំនួន**១.២០០**ដង មានអ្នកចូលរួមសរុបចំនួន**៦០.០០០**នាក់ ស្រី**២២.៤០០**នាក់។
- **ខេត្តកំពង់ស្ពឺ** បានផលិតបដា ពាក្យស្លោក ដែលមានខ្លឹមសារ “វិធានការច្បាប់ប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្ស” ចងនៅខាងមុខមន្ទីរ អង្គភាព ស្ថាប័នពាក់ព័ន្ធ និងនៅតាមវិទ្យាល័យនានាទូទាំងខេត្ត ចំនួន**០៤**លើក លើទីតាំង**១៧**កន្លែង ស្មើនឹង**៥៤**បដា។

# ខ. ការទារបទ្ទារទប់ស្កាត់ (ត)

- ខេត្តកំពង់ចាម អង្គការចាប់ដៃ បានធ្វើការជ្រើសរើសអ្នកតាមដានស្តាប់កម្មវិធីវិទ្យុ និងចែកខិត្តប័ណ្ណជំនួយ៥០០សន្លឹក ដល់ប្រជាពលរដ្ឋ។
- វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងនោះកងកម្លាំងនគរបាល វរៈការពារព្រំដែនគោក និងនគរបាលប៉ុស្តិ៍ តាមបណ្តាច្រករបៀងនៅខេត្ត៤ជាប់ព្រំដែនកម្ពុជា-ថៃ (**ខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិននិងខេត្តព្រះវិហារ**) បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ដោយមិនស្របច្បាប់ ឬតាមរយៈមេខ្យល់ បាន ៣០លើក ដល់មនុស្ស ៩៤៣នាក់ ស្រី ៣៣៦នាក់ និងកុមារ ៨៨នាក់ ។
- **ខេត្តបាត់ដំបង៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានចុះចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុក នៅតាមច្រកព្រំដែនកម្ពុជា-ថៃ ចំនួន១.០០០សន្លឹក។
  - មជ្ឈមណ្ឌលព័ត៌មានទីផ្សារការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែកខិត្ត ប័ណ្ណផ្សព្វផ្សាយ ចំនួន ១.៤៤៣សន្លឹក។
  - សមត្ថកិច្ចព្រំដែន បានសហការជាមួយអង្គការ Samaritan Purse ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុកចំនួន២.៧៩០នាក់ ស្រី១.០៤១នាក់ ដែលបញ្ជូនត្រឡប់មកពីប្រទេសថៃវិញ។

# ខ. ការទប់ស្កាត់ (ត)

**៨. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ** ដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋានរាជធានីខេត្ត ៖

- ពោធិ៍សាត់ ស្ទឹងត្រែង កែប ឧត្តរមានជ័យ មណ្ឌលគិរី រតនគិរី និងខេត្តព្រះវិហារ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងបានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន១៩៦គោលដៅ មានមនុស្សចំនួន១.៥៨៨នាក់ (ស្រី១.៣៤០នាក់) ។
- ខេត្តសៀមរាប ព្រៃវែង ឧត្តរមានជ័យ ស្វាយរៀង ពោធិ៍សាត់ កំពង់ធំ និងខេត្តកំពង់ស្ពឺ បានធ្វើការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**៣២៥**លើក ។
- ខេត្តព្រះសីហនុ ស្នងការដ្ឋាននគរបាល និងអង្គការម្លប់តាប៉ាង បានចុះចលនាដាក់បណ្តាញភ្នាក់ងារចំនួន**៦៣៣**នាក់ ដើម្បីធ្វើការពាក់ព័ន្ធសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី បណ្តាញសហគមន៍ បណ្តាញអ្នកលក់តាមឆ្នេរសមុទ្រ បុគ្គលិកតាមផ្ទះសំណាក់ និងសណ្ឋាគារ។

# ២. ការងារបង្ការទប់ស្កាត់ (ត)

**៨. ការតាមដានទិន្នន័យចំណាកស្រុក៖** ឆ្នាំ២០១៧ ពលករបានធ្វើចំណាកស្រុក ទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ ជាមធ្យម ជាង ៣០ម៉ឺននាក់ក្នុងមួយខែ ក្នុងនោះប្រមាណ ៤៤% មិនស្របច្បាប់ មានស្ត្រី ប្រមាណ ៤៣% និងកុមារ ប្រមាណ ២៥%

- ទិន្នន័យពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ពលករកម្ពុជាដែលអាជ្ញាធរបរទេសចំនួន១៨ប្រទេស បញ្ជូន ត្រឡប់តាមច្រកអន្តរជាតិ មានចំនួន១២៣.៥៦១នាក់ ស្រី ៤៥.៩៨៥នាក់ និងកុមារ ៧.៨៨១នាក់ (ក្នុងនោះ ពីប្រទេសថៃ ចំនួន១២២.៦៣០នាក់ កូរ៉េខាងត្បូង ៣២៣នាក់ ម៉ាឡេស៊ី២៨៩នាក់ វៀតណាម ៨៦នាក់ សិង្ហបុរី៣៨នាក់ ជប៉ុន២៦នាក់ ឥណ្ឌូនេស៊ី២០នាក់ ចិន៦៨នាក់ )។
- ក្នុងនោះ នគរបាលប្រឆាំងការជួញដូរមនុស្ស បានរកឃើញថា មានពលរដ្ឋខ្មែរចំនួន**៥.១០៨**នាក់ ត្រូវបានអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ លើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- អគ្គបញ្ជាការដ្ឋានកិច្ចការព្រំដែន នៃក្រសួងការពារជាតិ បានទទួល និងសម្ភាសន៍ពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន ២៧.៦៤០នាក់ ស្រី ៩.៦៧០នាក់ អនីតិជន ២.៨១២នាក់។
- មានសាកសព **<u>ពលរដ្ឋខ្មែរ បញ្ជូនពីប្រទេសថៃ ចំនួន២០៦លើក សរុបចំនួន២១១ សាកសព(ស្រី៤៣សព</u>**
- ស្ទើរតែរៀងរាល់ថ្ងៃ ខេត្តបន្ទាយមានជ័យ បានទទួលពលករខ្មែរ ដែលអាជ្ញាធរថៃដឹកជញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «និរទេស» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន១.៦៥៧ជើងរថយន្ត សរុបមានមនុស្សចំនួន ៧៣.២៧៥នាក់ ស្រី២៥.៥៨០នាក់ ក្នុងនោះកុមារ ៧.៣២៩នាក់ កុមារី៣.៨៧៧នាក់ (បើប្រៀបធៀបនឹងឆ្នាំ២០១៦ មានចំនួនតែ៣៩.៩៨៧នាក់ កើនឡើងចំនួន៣៣.២៨៨នាក់ ស្មើ៨៣,២៤%)។
- ខេត្តបាត់ដំបង បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន៩៨៧លើក មានមនុស្សចំនួន ៥៦.៧២០ នាក់ ស្រី ២២.២៥០នាក់(កុមារសរុប ៨៩៥នាក់មានកុមារី ១៩៩នាក់)
- ខេត្តប៉ៃលិន បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ បានចំនួន១.២៤៦នាក់ មានស្រី៥១៧នាក់។

# ខ. ការទប់ស្កាត់ (ត)

**១០. ដំណោះស្រាយផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅក្រៅប្រទេស**

- គិតត្រឹមខែមេសាឆ្នាំ២០១៧ ពលករកម្ពុជាដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ មានពលករសរុបចំនួន **១.០៥៦.៣៥៨នាក់** (ស្រីចំនួន**៤២០.០០០**នាក់) រួមទាំងពលករកម្ពុជាផ្នែកនេសាទ ដែលនឹងផុតសុពលភាពប័ណ្ណ ពណ៌ស៊ីជម្ពូ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ចំនួនប្រមាណជា ៤៧.០០០នាក់ និងអ្នកដែលបានចូលស្នាក់នៅធ្វើការងារគ្មានឯកសារច្បាប់មានចំនួន **៣១០.០០០**នាក់។
- គិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧នេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ បានបើកផ្តល់សំណុំលិខិតផ្តល់ភាពស្របច្បាប់ ដល់ពលករបានចំនួន**៣២៥.១៩៩**នាក់ ក្នុងនោះមាន លិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជា ធ្វើការនៅបរទេស (OCWC)។
- គិតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ ការផ្តល់ឯកសារ សម្រាប់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជា មិនអាចបញ្ចប់បាន ហើយត្រូវបន្តដល់ ថ្ងៃទី៣០ ខែមិនា ឆ្នាំ ២០១៨ទៀត។

១១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស

- ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសបានធ្វើសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ពីក្រសួងមហាផ្ទៃ ចំនួន**១.៤១៣**គូ។ តាមរយៈការតាមដានសុខទុក្ខ នារីខ្មែរ ៥០នាក់ ដែលទទួលបានភាពស្របច្បាប់ ក្នុងការរៀបអាពាហ៍ពិពាហ៍ ទៅរស់នៅឯក្រៅប្រទេសគឺមានសេចក្តីសុខ និងពុំមានប្រឈមនឹងបញ្ហាជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍នោះទេ ។

# គ.ការងារអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌

## គ.១. ការងារបង្ក្រាប

- **គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>**
- បានបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន១៥៩ករណី (លើ៩២ករណីបើធៀបនឹងឆ្នាំ២០១៦ កើនឡើងចំនួន៦៧ករណី ស្មើនឹង ៧២.៨២%)។
- ឃាត់ខ្លួនជនសង្ស័យ និងបញ្ជូនទៅសាលាដំបូង បានចំនួន២០៣/១១៣នាក់ (កើនឡើងចំនួន៩០នាក់) ស្រី៦១នាក់ អនីតិជន១៧នាក់ ត្រូវបានចាប់ខ្លួន។
- ចំនួនជនសង្ស័យជាជនបរទេសចំនួន**២០**នាក់ មាន**០៨**សញ្ជាតិគឺៈ វៀតណាម **០៣**នាក់ អង់គ្លេស**០២**នាក់ ហូឡង់**០២**នាក់ ជប៉ុន**០១**នាក់ អាមេរិក**០១**នាក់ រុស្ស៊ី**០១**នាក់ ចិន**០៩**នាក់ និងឆេក**០១**នាក់។
- ជនរងគ្រោះ ដែលសង្គ្រោះបានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបបានចំនួន**៣៤៥/២៩៨**នាក់ (កើនចំនួន**៤៧**នាក់) ក្នុងនោះអាយុក្រោម១៥ឆ្នាំមាន**១៣៨**នាក់ អាយុពី១៥-១៧ឆ្នាំ មាន**៤០**នាក់ និងអាយុ១៨ឆ្នាំឡើង មាន**១៦៧**នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន**១២០**នាក់ ទៅអង្គការចំនួន**០៥**នាក់ និងទៅបញ្ជូនទៅគ្រួសារវិញបានចំនួន**២២០**នាក់)។

# គ.ការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ត)



## គ.២. ការងារផ្តន្ទាទោស

តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប ១៦៦ | ២៣ | ៦៩ | ៤ | ៨១ | ១១១ | ៧៧ | ១៥ | ៤ | ១០៧ | ៣ | ៥៦ |
| | ៩២នាក់ | | ៨៥នាក់ | | ១៨៨នាក់ | | ១៩នាក់ | | ១៦៦ករណី | | |

## គ.២. ការងារផ្តន្ទាទោស (ត)

### ៣-ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖

- ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត សរុប**៤៤២**ករណី រកឃើញ
    - ជនរងគ្រោះ**៥៦២**នាក់ (អនីតិជន**៣៤៩**នាក់)
    - ជនត្រូវចោទមានចំនួន**៤៩៦**នាក់ (អនីតិជន**៦២**នាក់)
    - នៅក្នុងឃុំចំនួន**៣៦៩**នាក់ (អនីតិជន**១១៩**នាក់) នៅក្រៅឃុំចំនួន**១៩៥**នាក់ (អនីតិជន**៥៣**នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះក្តីចំនួន**៣៧**ករណី លើកលែងការចោទចំនួន**០៣**ករណី និងកំពុងចាត់ការចំនួន**៤០២**ករណី

### ៤-ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ រាជធានី-ខេត្ត ៖

- ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុប**២៧០**ករណី រកឃើញ
    - ជនរងគ្រោះចំនួន**២៧៥**នាក់ (អនីតិជន**៩៨**នាក់)
    - ជនជាប់ចោទសរុប**៣២៣**នាក់ (ស្រី**៧០**នាក់) និង
    - បានធ្វើចំណាត់ការៈ ទោសព្យួរគ្មាន ពិន័យជាប្រាក់**០៣**នាក់ រួចផុតពីបទចោទចំនួន**០៤**ករណី រំលត់បណ្តឹងអាជ្ញាគ្មានចាត់ការរួច**៥៨**ករណី ផ្តន្ទាទោសពន្ធនាគារ ក្នុងឃុំ**១២៩**នាក់ ក្រៅឃុំ**៤៥**នាក់ និងកំពុងចាត់ការ**២០៨**ករណី។


ក្រាហ្វិកចំណាត់ការរបស់ចៅក្រមជំនុំជម្រះឆ្នាំ២០១៧ ប្រៀបធៀបនឹងឆ្នាំ២០១៦
350
300
250
200
150
100
50
0
138
150
155
270
275
323
ឆ្នាំ២០១៦
ឆ្នាំ២០១៧
ករណី
ជនរងគ្រោះ
ជនជាប់ចោទ

# ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

**១-ការកំណត់រកមុខសញ្ញាជនរងគ្រោះ និងជនសង្ស័យ តាមការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស)**

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖** ស្ថានទូត ស្ថានតំណាងនៅបរទេស បានទទួល ពលរដ្ឋខ្មែរដែលបរទេសបញ្ជូនត្រឡប់មកកម្ពុជា ហើយដែលរងគ្រោះដោយអំពើជួញដូរមនុស្ស មានចំនួន**៧៥៧**នាក់ (ស្រី**៣៥៣**នាក់) មានមកពី ៖

- ប្រទេសម៉ាឡេស៊ី ចំនួន**៣៥១**នាក់ (ស្រី**២២៦**នាក់)
- ប្រទេសថៃ ចំនួន**២៦០**នាក់ (ស្រី**៨៧**នាក់)
- ប្រទេសចិន ចំនួន**៥០**នាក់ (ស្រី**៥០**នាក់)
- ប្រទេសឡាវ ចំនួន**៣៣**នាក់ (ស្រី**០៣**នាក់)
- ប្រទេសសូម៉ាលី ចំនួន**១៨**នាក់
- ប្រទេសឥណ្ឌូនេស៊ី ចំនួន**១៨**នាក់ (ស្រី**០១**នាក់)
- ប្រទេសវៀតណាម ចំនួន**១៧**នាក់ (ស្រី**១៧**នាក់)
- ប្រទេសជប៉ុន ចំនួន**០៥**នាក់ (ស្រី**០៥**នាក់)
- ប្រទេសសឹង្ហបូរី ចំនួន**០៤**នាក់ (ស្រី**០៣**នាក់)
- អារ៉ាប៊ីសាអូឌីត ចំនួន**០១**នាក់ (ស្រី**០១**នាក់)។

ដោយឡែកអគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួល និងសម្ភាសន៍ពលករខ្មែរសង្ស័យរងគ្រោះចំនួន៣០៤នាក់(ស្រី១៨៩នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី១៤៦នាក់ (ស្រី៥៧នាក់) ក្នុងនោះ ទៅតាមក្រុមហ៊ុន ៤០នាក់ ។

របាយការណ៍**អង្គការ IOM** ឆ្នាំ២០១៧នេះ បានជួយសម្រួលការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋ ពលករ-ពលការិនី និងស្ត្រីខ្មែរសង្ស័យរងគ្រោះចំនួន២៩៤នាក់ ស្រី១១២នាក់ មកពីប្រទេសចំនួន៨ ផងដែរ ។

# ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ (ត)

**ឃ.២-ការទទួលជនសង្ស័យរងគ្រោះ**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា** (របាយការណ៍ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបមានចំនួន **២៥១**នាក់ (ស្រី**១២៧**នាក់) ។ សកម្មភាពមានដូចជា៖
- **ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** សហការជាមួយអង្គការ IOM អង្គការចាប់ដៃ និងអង្គការរតនៈ អង្គការ IJM និងអង្គការ Caritas បានទទួលជនសង្ស័យរងគ្រោះចំនួន**២៤៣**នាក់ (ស្រី**១១៥**នាក់) ដែលបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ មានមកពីប្រទេសៈ ម៉ាឡេស៊ី**១១៤**នាក់ ថៃ**៤៥**នាក់ ចិន**២១**នាក់ ឥណ្ឌូនេស៊ី**២១**នាក់ សូម៉ាលី**១៨**នាក់ វៀតណាម**១៦**នាក់ ជប៉ុន**០៦**នាក់ សិង្ហបុរី**០១**នាក់ និងអារ៉ាប់ប៊ីសាអូឌីត**០១**នាក់។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលជនសង្ស័យរងគ្រោះធ្វើមាតុភូមិនិវត្តន៍ចំនួន**៤៦**នាក់ (ស្រី**០១**នាក់ កុមារ**១៨**នាក់ កុមារី**០៨**នាក់ ទារិកា**០១**នាក់) ពីដៃគូខាងភាគីថៃ ។
- **មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ** បានទទួលស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ និងជួញដូរពលកម្ម ឆ្លងដែន សរុបចំនួន**១៣៣**នាក់
- **មន្ទីរសង្គមកិច្ចខេត្តស្វាយរៀង** បានទទួលប្រជាពលរដ្ឋកម្ពុជាចំណាកស្រុកមកពីប្រទេសវៀតណាមតាមរយៈអគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន**០៧**លើក មាន**៤៥**គ្រួសារ សរុបចំនួន**១០៥**នាក់ ស្រី**៦៤**នាក់។
- **អង្គការដៃគូ**បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សសរុបចំនួន**៣៤២**នាក់ ស្រី**១៣៦**នាក់ កុមារី**១៩៣**នាក់ តាមរយៈ៖ អង្គការរេណាសេរ**១០**នាក់ អង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice) **៤០**នាក់ អង្គការសង្គ្រោះជោគវាសនាកម្ពុជា(Destiny Rescue) **១៧១**នាក់ អង្គការបេសកកម្មទូទាំងពិភពលោក**០៩**នាក់ អង្គការសង្គ្រោះនិងថែទាំអន្តរជាតិស៊ីធីភ័យ**២២**នាក់ អង្គការHAGA**២៨**នាក់ អង្គការស្ពានក្តីសង្ឃឹមនៅកម្ពុជា**៤៨**នាក់ និងអង្គការពន្លកថ្មី (The Hard Place Comnunity)**១៤**នាក់។ ករណីរកឃើញមានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស**១៧៦**នាក់ ជួញដូរផ្លូវភេទ**៤៥**នាក់ ជួញដូរកម្លាំងពលកម្ម**១៧**នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម**១៣**នាក់ រំលោភបំពានផ្លូវភេទ**៨៤**នាក់ អំពើអាស**០៦**នាក់ និងពេស្យាចារ**០១**នាក់។

# ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ (ត)

**សំណងជនរងគ្រោះ៖**

- ដោយមានកិច្ចសហការ និងការគាំទ្រផ្នែកច្បាប់ ពីវិស័យតុលាការ និងអង្គការដៃគូនានា ក្នុងនោះ មាន អង្គការ មូលនិធិជួយជនរងគ្រោះ (LPN) ក្រសួងសង្គមកិច្ចថៃ អង្គការ IOM, IJM, Chabdai, LSCW ស្ថានទូត និងនគរបាលប្រទេសជប៉ុន ក្រុមហ៊ុន Tochigi, អង្គការ ISWAN ការិយាល័យ ម្ចាស់កប៉ាល់នេសាទ Nahamm III ជាដើម បានធ្វើឲ្យជនរងគ្រោះ ទទួលបាន**ការសងថ្លៃឈ្នួលពលកម្ម សំណងការខូចខាត និងប្រាក់ឧបត្ថម្ភដល់ជនរងគ្រោះ ជាបន្តបន្ទាប់ ។**
-

**ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- **សមាហរណកម្មជនរងគ្រោះ**
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ (ក្រុមការពារជនរងគ្រោះ)** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយបានសហការជាមួយ ស្ថានទូតខ្មែរប្រចាំប្រទេសពាក់ពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូមួយចំនួន ដូចជាអង្គការសម្ព័ន្ធចាប់ដៃអង្គការវិត្តនៈ អង្គការមេត្រីអន្តរជាតិ និងអង្គការ Caritas អង្គការចាប់ដៃ អង្គការHAGA អង្គការសុវត្ថិនៃកីសង្ឃឹមនៅកម្ពុជា អង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice) ក្នុងការជួយ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ទៅតាមសហគមន៍ និងវិលត្រឡប់មកប្រទេសខ្លួនវិញ សរុបចំនួន**១៨៨**នាក់ (ស្រី**១៧២**នាក់) កុមារ**០១**នាក់ (កុមារី**០៧**នាក់)។
- **កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះធ្វើអធិការកិច្ចការងារលើសហគ្រាស គ្រឹះស្ថាន ដើម្បី ពិនិត្យលក្ខខណ្ឌការងាររបស់កម្មករវ័យក្មេង ទប់ស្កាត់ពលកម្មកុមារ ចាត់វិធានការចំពោះសហគ្រាស គ្រឹះស្ថានដែលប្រព្រឹត្តល្មើសច្បាប់ និងបានដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរ ចំនួន២៤០នាក់ កុមារី៩៩នាក់។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប បានចុះអធិការកិច្ចពលកម្មកុមារនៅតាមទួតដូចំនួន២០ទួតដូ និងបនស្រង់សិតិកម្មករទ្រតដូចំនួន៤០កន្លែង ផ្សេងទៀត រកឃើញកំពុងដំណើរការតែ៣៧កន្លែង បិទដំណើរការ០៣កន្លែង និងផ្អាក០៥កន្លែង រកឃើញកម្មករសរុប៧៨៧នាក់ មានស្រី៣៨០នាក់។

# IV. ការលើកកម្ពស់សមត្ថភាព

**១. ក្នុងប្រទេស**

- **ការបណ្តុះបណ្តាលក្នុងប្រទេស សម្រាប់ការងារពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរមនុស្ស ត្រូវបានធ្វើឡើងដោយ**អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង សុខាភិបាល ក្រសួងកិច្ចការនារី អគ្គស្នងការដ្ឋាននគរបាលជាតិ និងខេត្តចំនួន១២ ព្រមទាំងបាន សហការជាមួយអង្គការដៃគូមួយចំនួន បើកវគ្គបណ្តុះបណ្តាលជាសរុបបានចំនួន**១០៦**វគ្គ មានសិក្ខាកាមចូលរួមចំនួន**៦.៥៣៥**នាក់ ក្នុងនោះមានស្ត្រី**២.៨១៤**នាក់ ។
- **សន្និសីទ ថ្នាក់អន្តរជាតិ ត្រូវបានរៀបចំ អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរៀបចំសន្និសីទអាស៊ី-អ៊ឺរ៉ុបលើកទី១៤ ស្តីពីការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅខេត្តសៀមរាប មានសមាជិកចូលរួមចំនួន**៦៤**នាក់ មកពី**២៥**ប្រទេស។
- កិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស មាន**៤៩១**លើក មានអ្នកចូលរួមសរុប**៧.៤២៥**នាក់ មានស្រី**២.២៥៥**នាក់ ។

# IV. ការលើកកម្ពស់សមត្ថភាព (ត)

**២. នៅក្រៅប្រទេស**

- ***វគ្គបណ្តុះបណ្តាល***៖ បានបញ្ជូន មន្រ្តីជំនាញ ដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងខេត្តកំពត ទៅចូលរួមវគ្គបណ្តុះបណ្តាល នៅក្រៅប្រទេស បានចំនួនសរុប ៥៨នាក់ ។
- **សិក្ខាសាលា៖** អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ក្រសួងកិច្ចការនារី និងក្រសួង អង្គភាពពាក់ព័ន្ធ បានដឹកនាំប្រតិភូកម្ពុជា និងបញ្ជូនថ្នាក់ដឹកនាំ និងមន្រ្តីជំនាញទៅចូលរួមសិក្ខាសាលាក្រៅប្រទេស បាន ០៩លើក មានមន្រ្តីកម្ពុជាសរុប ២៦នាក់។
- **កិច្ចប្រជុំ**៖ បានបញ្ជូនមន្រ្តី ៦១នាក់ ពីក្រសួង អង្គភាពពាក់ព័ន្ធ ចូលរួមកិច្ចប្រជុំ អន្តរជាតិ នៅក្រៅប្រទេស បាន ១៤លើក និងកិច្ចប្រជុំជំនាញរវាងខេត្តជាប់ព្រំដែន បន្ទាយមានជ័យ ព្រះវិហារ និងខេត្តរតនគិរី ស្តីពីកិច្ចសហការ ក្នុងការបញ្ជូនត្រឡប់ ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ តាមបណ្តោយព្រំដែន និង ការដោះស្រាយបញ្ហាប្រជាជនឆ្លងដែនខុសច្បាប់ ។
- **សន្និសីទ ៖**
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្រ្តៃយ៍ គ.ជ.ប.ជ បានចូលរួមសន្និសីទអាស៊ាន ស្តីពីសារសំខាន់នៃបញ្ហាផ្តែកច្បាប់ ក្នុងតំបន់នៅប្រទេសសិង្ហបុរី
- កិច្ចប្រជុំពិភាក្សាលើការរៀបចំកតិកាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ទីក្រុងបាងកក ប្រទេសថៃ ទីក្រុងម៉ិកស៊ិកូ ប្រទេសម៉ិកស៊ិច និងនៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

# V. ការសន្និដ្ឋាន វាយតម្លៃ

## ក.ចំណុចខ្លាំង

- ចំណុចខ្លាំងនៃយន្តការ ក្នុងការអនុវត្តសកម្មភាពនេះគឺៈ
- ឆន្ទៈ និងការប្តេជ្ញាចិត្តជានយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកំណត់យកបញ្ហាជួញដូរមនុស្សជាអាទិភាពមួយ ដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយជាបន្ទាន់។
- ការសម្រេចចិត្តជាយុទ្ធសាស្រ្តរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ បញ្ចៀសបញ្ហាប្រឈមដែលពលករខុសច្បាប់នៅក្រៅប្រទេស
- គោលនយោបាយលើកកម្ពស់ជីវភាព និងស្ថានភាពរស់នៅរបស់កម្មករក្នុងស្រុកធ្វើឲ្យមានតុល្យភាពសម្រាប់ជម្រើសជូនប្រជាពលរដ្ឋកម្ពុជា ជៀសវាងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដែលប្រឈមនឹងអំពើជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។
- វិធានការជាគន្លឹះ ជាបន្តបន្ទាប់ របស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ សម្រាប់ជំរុញការអនុវត្តយន្តការសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ ។
- មានឧបករណ៍ច្បាប់និងកិច្ចព្រមព្រៀងនានា ទ្វេភាគី ពហុភាគី និងដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា ទទួលអនុវត្ត ជាពហុភាគី ទ្វេភាគី ជាមួយប្រទេសពាក់ព័ន្ធនានាក្នុងតំបន់ និងលើសកលលោក លើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធនានា ។
- ការលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើន គឺជាមូលដ្ឋានបង្អែករឹងមាំ សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមានក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន បានរួមគ្នាជាកម្លាំងស្នូល និងបានបង្កើនសមត្ថភាពបំពេញភារកិច្ចយ៉ាងសកម្ម ដើម្បីក្លាយទៅជាប្រព័ន្ធសុវត្ថិភាពដ៏រឹងមាំ សម្រាប់ការពារសុវត្ថិភាពជនគ្រប់រូប ទាំងបុរស ស្រ្តី យុវវ័យ និងកុមារ ពីអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

# V. ការសន្និដ្ឋាន វាយតម្លៃ (ត)

## ខ. ចំណុចប្រឈម និងចំណុចខ្វះខាត

ប្រជាពលរដ្ឋ នៅតែបន្តចាញ់ឧបាយកលជនឧក្រិដ្ឋដែលមានល្បិចកលខ្ពស់ និងមានបណ្តាញប្រទាក់ក្រឡាយ៉ាងស្មុគស្មាញ ក្នុងការកេងប្រវ័ញ្ច និងជួញដូរមនុស្ស ។

- ការត្រួតពិនិត្យ និងគ្រប់គ្រងពលករចំណាកស្រុកតាមច្រកព្រំដែន មិនទាន់បានល្អ ដែលបន្តឲ្យមានភាពរងគ្រោះ និងការខាតបង់នៅក្នុងប្រទេសគោលដៅមិនមានសេសសល់ផលកម្រៃពលកម្មឲ្យបាន សក្តិសម និងមិនទាន់អាចទាញយកសក្តានុពលចំណូលពីពលកម្មក្រៅប្រទេសបានពេញលេញ។
- ការតាមដានស្ថានភាព និងគាំទ្រដល់ជនរងគ្រោះឬអ្នកវិលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ មិនទាន់ក្លាយជាប្រព័ន្ធនៅឡើយ។
- មន្ត្រីមួយចំនួនទើបផ្លាស់ប្តូរតួនាទី ត្រូវការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីអាចទទួលខុសត្រូវ អនុវត្តការងារជំនាញដែលខ្លួនទទួលខុសត្រូវឲ្យមានប្រសិទ្ធភាព
- ការផ្តល់ព័ត៌មាន និងការបញ្ជូនរបាយការណ៍ របស់ក្រសួង ស្ថាប័ន អង្គភាព និងលេខាធិការដ្ឋានខេត្ត មួយចំនួន នៅតែយឺតយ៉ាវ មិនទាន់ហេតុការណ៍ ។
- រាជធានី-ខេត្ត អង្គភាពស្ថាប័នមួយចំនួន មិនទាន់បានត្រៀមផែនការសកម្មភាព និងថវិកាច្បាស់លាស់នៅឡើយ។
- ត្រូវការយុទ្ធសាស្ត្រនៃការបង្កាទប់ស្កាត់ ដើម្បីបានជ្រួតជ្រាប និងអនុវត្តក្នុងការកែប្រែទស្សនៈ និងការគិតងាយក្នុងការធ្វើចំណាកស្រុក ។
- ជនទេសន្តរប្រវេសន៍ខុសច្បាប់ ត្រូវបានឃាត់ខ្លួន ដកហូត ផាកពិន័យ ជួញដូរ កេងប្រវ័ញ្ច ។ល។
- ការដោះស្រាយផ្តល់ភាពស្របច្បាប់ក្នុងប្រទេសគោលដៅ គឺជាដំណោះស្រាយបណ្តោះអាសន្ន មិនអាចបន្តជារៀងរហូតទេ ។
- ការបង្ក្រាប បណ្តាញជនល្មើស ដែលមានភាពប្រទាក់ក្រឡា ពីប្រទេសមួយទៅប្រទេសមួយ មិនអាចធ្វើបាន ដោយគ្មានកិច្ចសហការល្អរវាងប្រទេសពាក់ព័ន្ធឡើយ ។
- ការរីកដុះដាលឡើងវិញនូវសេវាកម្មឡានក្តុ «ភ្លើងពណ៌» ដែលជាប្រភពនៃការជួញដូរផ្លូវភេទ។
- ផលប៉ះពាល់លើកុមារដែលនៅក្នុងគ្រួសារជនទេសន្តរប្រវេសន៍ មានទំហំកាន់តែធំ ទោះបីជាកុមារទាំងនោះត្រូវបានឪពុកម្តាយដែលធ្វើទេសន្តរប្រវេសន៍បោះបង់ឲ្យរស់នៅជាមួយអ្នកជិតខាង សាច់ញាតិ ឬចាស់ទុំក្តី ឬទៅតាមឪពុកម្តាយនៅពេលធ្វើទេសន្តរប្រវេសន៍ក្តី ព្រោះ ក្មេងទាំងនោះ នឹងមិនមាន ឱកាសទទួលបានការរៀនសូត្រ ថែទាំសុខភាព និងសុវត្ថិភាព ដូចក្មេងដទៃឡើយ។
- ការសាងសង់មណ្ឌលសំចត នៅតាមបណ្តាច្រកព្រំដែនសំខាន់ៗ ដើម្បីទទួលពលករ និងត្រៀមដោះស្រាយបញ្ហាពលករ នៅយឺតយ៉ាវ មិនទាន់ដំណើរការ។

# V. ការសន្និដ្ឋាន វាយតម្លៃ (ត)

ក. សន្និដ្ឋាន

- អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទ នៅតែបន្តកើតមាន ។
- ការគ្រប់គ្រងលំហូរមិនប្រក្រតីនៃជនទេសន្តរប្រវេសន៍ នៅមិនទាន់មានប្រសិទ្ធភាព ។
- ការផ្តល់ភាពស្របច្បាប់ នៅមានភាពស្មុគស្មាញ មិនទាន់មានភាពច្បាស់លាស់ ទាំងនៅក្នុងប្រទេស និងនៅប្រទេសគោលដៅ ។
- យុទ្ធសាស្ត្រទាំងបួន ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតែមានសារៈសំខាន់ក្នុងការអនុវត្ត។
- គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ចាំបាច់ត្រូវបន្តពង្រឹងយន្តការ ទាំងសមត្ថភាពយល់ដឹងជំនាញ ការតាមដាន ការគ្រប់គ្រងសភាពការណ៍ ការគ្រប់គ្រងទិន្នន័យ និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នអនុវត្ត និងកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ជាពិសេស រវាងប្រទេសបញ្ជូន និងប្រទេសគោលដៅ គឺជាកត្តាចាំបាច់ និងគន្លឹះមិនអាចខ្វះបាន ដើម្បីអាចឆ្លើយតប និងដោះស្រាយបញ្ហាភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ពីអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្សបាន។

# VI. ទិសដៅ ឆ្នាំ២០១៨

## ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការៈ

១. ប្រមូល និងចងក្រងលិខិតុបករណ៍ជាតិ ឯកសារកិច្ចព្រមព្រៀងទ្វេភាគី-ពហុភាគី ជាមួយបណ្តាប្រទេសនានា ដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២.ត្រៀមចុះហត្ថលេខា និងអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជម្រុញការអនុវត្តជាមួយប្រទេសពាក់ព័ន្ធដទៃទៀតដែលមានអនុស្សរណៈ ឬកិច្ចព្រមព្រៀងជាមួយកម្ពុជា ។

៣. ត្រៀមកិច្ចប្រជុំ ប្រចាំឆ្នាំលើកទី២ កម្ពុជា-ចិន នៅរាជធានីភ្នំពេញ ។

៤. ក្រុមការងារខមមីតកម្ពុជា ត្រៀមចូលរួមកិច្ចប្រជុំពិនិត្យសម្រេចលើកិច្ចព្រមព្រៀងទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសម៉ាឡេស៊ី(ខែមេសា ឆ្នាំ២០១៨)។

៥. ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាប្រទេសនានា ក្នុងតំបន់ និងក្នុងពិភពលោក ដើម្បីធ្វើឲ្យការងារបង្ការទប់ស្កាត់ បង្ក្រាប សង្គ្រោះ និងការពារជនរងគ្រោះ និងជនងាយរងគ្រោះ ពីអំពើជួញដូរមនុស្សគ្រប់រូបភាពអាចទទួលបានជោគជ័យ ។

៦. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន(កម្ពុជា ឡាវ ភូមា) និងប្រទេសទទួល (ថៃ) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

# VI. **ទិសដៅ ឆ្នាំ២០១៨(ត)**

## **ខ. ការងារបង្ការទប់ស្កាត់**៖

១. បន្តជម្រុញយុទ្ធនាការប្រឆាំងការជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបន្តការងារផ្សព្វ ផ្សាយអប់រំតាមគ្រប់រូបភាព ដោយប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសាកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ដើម្បីបញ្ជ្រាបការយល់ដឹងជាប្រចាំតាមរយៈវេទិកាសហគមន៍នានាឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុង និងក្រៅសាលារៀនដែលងាយរងគ្រោះ ។

២. រៀបចំយន្តការអន្តរស្ថាប័ន និង«វិធានការ**គ្រប់គ្រងលំហូរមិនប្រក្រតីឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋ**» និងលើកកម្ពស់ទេសន្តរប្រវេសន៍ដែលមានសុវត្ថិភាព រៀបរយ និងស្រប ច្បាប់ (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

៣. បង្កើតយុទ្ធសាស្ត្របង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងដោយជម្រុញអនុវត្តតាមគោលដៅអាទិភាព ។

# VI. ទិសដៅ ឆ្នាំ២០១៨(ត)

## គ. ការងារការពារជនរងគ្រោះ៖

១. បន្តសកម្មភាពបណ្តុះបណ្តាល មន្ត្រីមានសមត្ថកិច្ចកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ។

២. តាមដាន និងចងក្រងទិន្នន័យជនរងគ្រោះ ដោយសហការជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូនានា ក្នុងរាជធានីខេត្តគោលដៅ បង្កើតក្រុមអភិឌ្ឍន៍ខ្លួនឯង និងលើកវិធានការផ្តល់កិច្ចការពារ ឬគម្រោងនានា ដើម្បីបង្ការទប់ស្កាត់ការវិលត្រឡប់ទៅរងគ្រោះជាថ្មី។

៣. ចុះតាមដាន វាយតម្លៃ និងចងក្រងបទពិសោធន៍ល្អៗក្នុងការអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងកិច្ចការពារ និងអភិវឌ្ឍន៍ជនរងគ្រោះ។

# VI. ទិសដៅ ឆ្នាំ២០១៨( ត )

## គ. **ការងារអនុវត្តច្បាប់ និងកិច្ចការយុត្តិធម៌៖**

១. បន្តកិច្ចសហការជាមួយសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីស្រាវជ្រាវ ស៊ើបអង្កេតរកបទល្មើស ឧក្រិដ្ឋជន និងអ្នកពាក់ព័ន្ធ ដើម្បីផ្តន្ទាទោសតាមច្បាប់ និងពង្រឹងការអនុវត្តច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. បន្តបណ្តុះបណ្តាលមន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស នៅសាលាបណ្ឌិត្យសភានគរបាល និងសាលានគរបាលភូមិភាគ នូវមេរៀនស្តីពី នីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ដែលបានដាក់បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលរួចហើយ ។

៣. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់តាមបណ្តារាជធានី ខេត្ត ដើម្បីជម្រុញការស៊ើបអង្កេត និងបង្ក្រាប ឲ្យមានប្រសិទ្ធភាព ។

៤. ជម្រុញ ការអនុម័តច្បាប់ស្តីពី“**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**” **(MLA)** និងពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យ យុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។

៥. ជម្រុញការអនុម័តច្បាប់ស្តីពី “**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**” និង ជម្រុញការចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគី **ស្តីពី“ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ”** ជាមួយសាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋបារាំង និងសាធារណរដ្ឋកូរ៉េ។

# VI. ទិសដៅ ឆ្នាំ២០១៨(ត)

## ឃ. ការគាំទ្រ និងតាមដានត្រួតពិនិត្យ៖

១.	គាំទ្រ និងពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដើម្បីពង្រឹងការគ្រប់គ្រងរបៀបរបបការងាររបស់ លេខាធិការដ្ឋានរាជធានី-ខេត្ត និងក្រុមការងារ ទាំង៦។

២. រៀបចំផែនការយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល ៥ឆ្នាំ (២០១៩-២០២៣) និងផែនការសកម្មភាពប្រចាំឆ្នាំ២០១៩ ។

៣.	បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីដែលបានចុះហត្ថលេខារួចហើយ និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៤.	ជំរុញតាមដាន ត្រួតពិនិត្យក្រុមហ៊ុនដែលបានបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ ។

៥.	បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល។

# VI. **ទិសដៅ ឆ្នាំ២០១៨ ( ត )**

ទិសដៅបន្ថែម ដែលជាអនុសាសន៍**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** ក្នុងកិច្ចប្រជុំឆមាសទី១៖

១.ជំរុញអនុវត្តវិធានការដោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

២. ស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ក្នុងស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា ទំនាក់ទំនងអប់រំ និងផ្តល់សេវា ។

៣.ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនពលករត្រឡប់ពីប្រទេសថៃ ដោយមានមន្ត្រីប្រចាំការសម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនបានចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពពលករជាដើម។

# សូមគោរពថ្លែងអំណរគុណ